នស/រកម/០៧០២/០១៤

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី វិស័យប្រៃសណីយ៍ ដែលរដ្ឋសភាបានអនុម័តកាល ពីថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៨ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើទី ៧ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅ :

# ច្បាប់

# ស្តីពី

# វិស័យព្រៃឈើ

## ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលដៅកំណត់លើការងារសេវាកម្ម អាជីវកម្មប្រៃសណីយ៍ក្នុងនិងក្រៅប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ។

ការងារសេវាកម្មនិងអាជីវកម្មប្រៃសណីយ៍គ្រប់ប្រភេទនៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅក្រោមសមត្ថកិច្ចដឹកនាំគ្រប់គ្រងនិងចាត់ចែងដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

មាត្រា ២.-

ការងារសេវាកម្មនិងអាជីវកម្មប្រៃសណីយ៍ ត្រូវបំរើប្រជាពលរដ្ឋគ្រប់រូប ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ និន្នាការនយោបាយនិងសាសនា ។

មាត្រា ៣.-

ច្បាប់នេះមានវិសាលភាពអនុវត្តលើសេវាប្រៃសណីយ៍ :

- សេវាបញ្ញើប្រៃសណីយ៍
- សេវាបញ្ញើឆាប់រហ័ស
- សេវាបញ្ញូនប្រាក់តាមប្រៃសណីយ៍
- សេវាបញ្ជូនតាមរូបភាពទូរគមនាគមន៍ និង
- សេវាប្រៃសណីយ៍តាមសំណូមពរ ។

មាត្រា ៤.-

បញ្ញើប្រៃសណីយ៍ត្រូវបានបែងចែកជាពីរប្រភេទគឺ បញ្ញើសំបុត្រប្រៃសណីយ៍ និងបញ្ញើប្រៃសណីយ៍ភណ្ឌ ។

បញ្ញើសំបុត្រប្រៃសណីយ៍រួមមាន : សំបុត្រ ប្រៃសណីយ៍ប័ត្រ កលិកប័ត្រ កញ្ចប់តូចនិងសម្ភារៈសិក្សាសំរាប់មនុស្សខ្វាក់ ។

សំបុត្រគឺជាលិខិត ឬកញ្ចប់លិខិតដែលមានលក្ខណៈជាទំនាក់ទំនងពត៌មានរបស់បុគ្គល និងត្រូវបានបិទជិត ។

ប្រៃសណីយ៍ប័ត្រគឺជាប្រភេទប័ណ្ណធ្វើអំពីក្រដាសរឹង មានទំហំជាកំណត់និងមានកន្លែងសរសេរពត៌មាននៅខាងខ្នង សំរាប់ប្រើប្រាស់ក្នុងការបញ្ជូនពត៌មានខ្លី ដោយពុំត្រូវបានប្រើស្រោមសំបុត្រ ។

កលិកប័ត្រគឺជាបណ្ណាសារពត៌មាន ទស្សនាវដ្តី ឯកសារបោះពុម្ពនិងគ្មានលក្ខណៈជាទំនាក់ទំនងបុគ្គល ដោយគ្រាន់តែជាការផ្សព្វផ្សាយពត៌មាននិងធ្វើជាចំហ ។

កញ្ចប់តូច គឺជាបញ្ញើប្រៃសណីយ៍មួយដែលវត្ថុបញ្ញើត្រូវបានខ្ចប់បិទជិត មានទំហំជាកំណត់ និងមានទម្ងន់មិនលើសពី ២ គីឡូក្រាម ។

សម្ភារៈសិក្សាសម្រាប់មនុស្សខ្វាក់រួមមាន : ថាសរំរៀង ខ្សែអាត់ ប្រដាប់ពិសេសបង្កើតដោយមន្ទីរពិសោធន៍របស់សាលារៀនសម្រាប់មនុស្សខ្វាក់ និងអក្សរអណ្តែតត្រូវបានខ្ចប់ជិតបិទជិត ។

ប្រៃសណីយ៍ភណ្ឌគឺជាវត្ថុបញ្ញើដែលត្រូវបានខ្ចប់បិទជិតដោយកាតុងរឹង ឬហិបក្តុង ទំហំ និងទម្ងន់ដែលត្រូវកំណត់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

មាត្រា ៥.-

សេវាបញ្ញើឆាប់រហ័សពិសេស គឺជាសេវាកម្មប្រៃសណីយ៍ទំនើបពិសេសមួយដែលត្រូវបានរៀបចំឡើងក្នុងប្រព័ន្ធសេវាមានលក្ខណៈជាអន្តរជាតិ ។ សេវានេះធានាទូវសុវត្ថិភាព និងមានអាទិភាពលើសសេវាប្រៃសណីយ៍ដទៃទៀត ដោយធ្វើការទទួលផ្ញើ ការបញ្ជូនចេញ និងការបែងចែកយ៉ាងឆាប់រហ័ស ។

មាត្រា ៦.-

ប្រៃសណីយ៍បញ្ជូនប្រាក់ គឺជាការបញ្ជូនប្រាក់របស់អតិថិជនតាមផ្លូវប្រៃសណីយ៍ និងទូរគមនាគមន៍នៅក្នុងប្រទេសនិងក្រៅប្រទេស ក្រោមរូបភាពអាណត្តិប្រៃសណីយ៍ ឬអាណត្តិទូរលេខ ។

មាត្រា ៧.-

សេវាប្រៃសណីយ៍បញ្ជូនតាមរូបភាពទូរគមនាគមន៍ គឺជាសេវាប្រៃសណីយ៍តាមបច្ចេកវិទ្យាទំនើបដែលបញ្ជូនលិខិត ឬពត៌មានតាមឧបករណ៍អេឡិចត្រូនិក ឬអេឡិចត្រូម៉ាញ៉េទិករបស់វិស័យទូរគមនាគមន៍ ។

មាត្រា ៨.-

ប្រៃសណីយ៍ផ្តល់នូវសេវាតាមសំណូមពរបន្ថែម លើបណ្តាសេវានានាដែលមានចែងក្នុងមាត្រា ៤ ដូចជា :

- ការបញ្ជូនតាមយន្តហោះ
- បញ្ញើរហ័ស
- បញ្ញើអនុសិដ្ឋ
- ការផ្តល់ដំណឹងឆ្លើយតបពីការបានទទួល
- ការសុំប្រើប្រាស់អាស័យដ្ឋានប្រអប់ប្រៃសណីយ៍ និងប្រៃសណីយ៍តម្កល់ទុក
- បញ្ញើមានប្រកាសតម្លៃ
- បញ្ញើសងប្រាក់ក្នុងពេលទទួល
- បញ្ញើផ្សាយពាណិជ្ជកម្ម
- ការធានា និងថែរក្សាបញ្ញើ ដែលងាយបែកបាក់ ឬប្រេងប្រេងាង
- ការផ្ញើត្រឡប់មកម្ចាស់ដើមវិញ ក្នុងករណីបញ្ញើមិនបានដល់គោលដៅ

## ជំពូកទី ២

## ទិដ្ឋភាព ការពារសិទ្ធិ មិនរំលោភលើអាថ៌កំបាំង នៃបញ្ញើប្រៃសណីយ៍

មាត្រា ៩.-

រាល់បញ្ញើតាមប្រៃសណីយ៍ទាំងអស់ជាកម្មសិទ្ធិរបស់អ្នកផ្ញើ ហើយត្រូវបានរក្សាសុវត្ថិភាពនិងអាថ៌កំបាំង ចាប់ពីពេលទទួលរហូតដល់ខណៈពេលដែលបញ្ញើទាំងនេះធ្លាក់ដល់ដៃអ្នកទទួល លើកលែងតែវត្ថុបញ្ញើទាំងឡាយណាដែលច្បាប់ហាមឃាត់ ឬពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ ។

**មាត្រា ១០.-**

ការធានាសិទ្ធិមិនឱ្យរំលោភលើអាថ៌កំបាំងនៃសំបុត្រត្រូវបានធានាតាមវិធានដូចខាងក្រោម :

១-ហាមបើក ឬធ្វើផ្សេងទៀតដែលអាចឱ្យដឹងអំពីខ្លឹមសារនៃសំបុត្រដែលត្រូវបានបិទជិត

២-ហាមផ្តល់ពត៌មានអំពីដំណើរប្រៃសណីយ៍នៃសំបុត្ររបស់អ្នកណាម្នាក់ ឬអំពីខ្លឹមសារនៃសំបុត្រនោះឱ្យទៅអ្នកដទៃ

៣-ហាមផ្តល់លទ្ធភាព ឬជួយដល់ទង្វើទាំងឡាយខាងលើ ។

ការហាមឃាត់ក្នុងបទប្បញ្ញត្តិនៃវាក្យខ័ណ្ឌ ១ កថាខ័ណ្ឌ ១ ត្រូវបានលើកលែងចំពោះករណីចាំបាច់ត្រូវធ្វើសំរាប់សេវាប្រៃសណីយ៍ ក្នុងករណីសំបុត្រជាបញ្ញើសំណល់ ។ បញ្ញើសំណល់គឺជាបញ្ញើប្រៃសណីយ៍ដែលមិនមានបញ្ជាក់អំពីអាស័យដ្ឋានច្បាស់ជាប្រាកដ ដើម្បីបំពេញការបញ្ជូនប្រៃសណីយ៍ទៅអ្នកទទួល ឬត្រឡប់ទៅអ្នកផ្ញើវិញ ។

**មាត្រា ១១.-**

ការធានាសិទ្ធិមិនឱ្យរំលោភលើអាថ៌កំបាំងនៃកញ្ចប់តូចនិងប្រៃសណីយ៍ភណ្ឌត្រូវបានធានាតាមវិធានដូចខាងក្រោម :

១-ហាមបើកវត្ថុបញ្ញើដែលត្រូវបានបិទជិត

២-ហាមផ្តល់ពត៌មានអំពីដំណើរប្រៃសណីយ៍នៃបញ្ញើរបស់អ្នកណាម្នាក់ ឬអំពីខ្លឹមសារនៃវត្ថុបញ្ញើនោះឱ្យទៅអ្នកដទៃ

៣-ហាមផ្តល់លទ្ធភាព ឬជួយដល់ទង្វើទាំងឡាយខាងលើ ។

**មាត្រា ១២.-**

ការហាមឃាត់ក្នុងបទប្បញ្ញត្តិនៃមាត្រា ១១ ចំណុច ១ ត្រូវបានលើកលែងចំពោះករណីចាំបាច់ត្រូវធ្វើសំរាប់សេវាប្រៃសណីយ៍ដូចជា :

ក-ការពិនិត្យដោយប្រៃសណីយ៍លើវត្ថុក្នុងបញ្ញើបិទជិត ងាយស្រួលដល់ការវិនិច្ឆ័យលើថ្លៃសេវានិងអាករ

ខ-ការរៀបចំឱ្យមានសុវត្ថិភាពដោយប្រៃសណីយ៍ចំពោះបញ្ញើណាដែលខូចខាត

គ-ក្នុងករណីបញ្ញើសំណល់ ដូចមានចែងក្នុងមាត្រា ១០ ចំណុច ២ ។

ការហាមឃាត់ក្នុងបទប្បញ្ញត្តិនៃមាត្រា ១១ ចំណុច ២ ត្រូវបានលើកលែងចំពោះករណីចាំបាច់ពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ ។ ការទាមទារឱ្យផ្តល់ព័ត៌មានអំពីពិពណ៌នានៃបញ្ញើរបស់អ្នកណាម្នាក់ ឬការទាមទារឱ្យប្រគល់នូវរបស់បញ្ញើទាំងនោះអាចធ្វើទៅបាន លុះត្រាតែមានដីកាតុលាការដែលបញ្ជាក់ច្បាស់លាស់ទៅលើបញ្ញើណាមួយជាក់ច្បាស់ ។

មាត្រា ១៣.-

ការផ្តល់ព័ត៌មានអំពីដំណើរសេវាបញ្ញើប្រាក់តាមប្រៃសណីយ៍ អនុញ្ញាតឱ្យធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីម្ចាស់បញ្ញើ វៀរលែងតែក្នុងករណីជាករណីយកិច្ចផ្តល់ព័ត៌មានដែលច្បាប់តម្រូវឱ្យធ្វើ ឬមានដីកាតុលាការដែលបញ្ជាក់ច្បាស់លាស់ទៅលើបញ្ញើណាមួយជាក់ច្បាស់ ។

## ជំពូកទី ៣

## សមត្ថកិច្ចរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

មាត្រា ១៤.-

ការកំណត់តម្លៃនិងការបោះពុម្ពតែមប្រៃសណីយ៍ លិខិតអេរ៉ូក្រាម ប័ណ្ណប្រៃសណីយ៍ និងការប្រើប្រាស់ម៉ាស៊ីនតែមប្រើសម្រាប់បំពេញការងារក្នុងវិស័យប្រៃសណីយ៍ជាសមត្ថកិច្ចរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

មាត្រា ១៥.-

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ កំណត់តម្លៃសេវា ទូទាត់តម្លៃសេវាអន្តរជាតិរវាងបណ្តាប្រទេសលើពិភពលោក ដោយអនុវត្តតាមអនុសញ្ញាសហភាពប្រៃសណីយ៍សកល និងយកប្រាក់និមិត្តរូបមួយមកអនុវត្ត ដែលកំណត់ការប្តូរប្រាក់ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ ។

មាត្រា ១៦.-

មានតែក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ទេ ដែលជាអ្នកផ្តល់អាជ្ញាប័ណ្ណធ្វើអាជីវកម្មប្រៃសណីយ៍ ។ អាជីវកម្មឯកជនក្នុងវិស័យប្រៃសណីយ៍អាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាតជាមុន តាមរូបភាពអាជ្ញាប័ណ្ណពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ ការផ្តល់អាជ្ញាប័ណ្ណនឹងមានចែងលំអិតក្នុងជំពូកទី ៥ នៃច្បាប់នេះ ។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវរៀបចំទីតាំងប្រៃសណីយ៍និងប្រអប់សំបុត្រអពិន្ត្រៃយ៍តាមផ្លូវសាធារណៈ ។

មាត្រា ១៧.-

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវរៀបចំផ្លូវប្រៃសណីយ៍របស់រដ្ឋមួយដោយឡែកទៀត សំរាប់ធានាសុវត្ថិភាពពិសេសចំពោះបញ្ញើនៃស្ថាប័នរដ្ឋនិងបញ្ញើការទូត ។

មាត្រា ១៨.-

ដើម្បីឱ្យការអនុវត្តន៍ច្បាប់នេះមានប្រសិទ្ធភាព ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានសមត្ថកិច្ចកំណត់លិខិតបទដ្ឋាននានាស្តីពី :

-តម្លៃសេវាប្រៃសណីយ៍ តម្លៃសេវាបន្ទាប់បន្សំនិងតម្លៃសេវាលើអាណត្តិគ្រប់ប្រភេទ ព្រមទាំងប្រាក់សំណងលើការបាត់បង់បញ្ញើ

-បញ្ញើរួចតម្លៃសេវា និងអ្នកមានសិទ្ធិរួចតម្លៃសេវា

-បែបបទបច្ចេកទេសនិងរយៈពេលបញ្ជូន ទទួល ចែកចាយ និងករណីចែកពុំបាន

-របៀបវេចខ្ចប់ និងកំណត់ទម្ងន់ និងទំហំនៃប្រភេទបញ្ញើនីមួយៗ

-ការវិនិច្ឆ័យបញ្ញើសំណល់

-ការផ្តល់អប្បហារ ឬកម្រៃ ។

## ជំពូកទី ៤
## សេវាប្រៃសណីយ៍

**មាត្រា ១៩.-**

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍រៀបចំឱ្យមានការផ្តល់សេវាកម្មប្រៃសណីយ៍ទាំងអស់ ដូចមានចែងក្នុងមាត្រា ៣ នៃច្បាប់នេះជូនសាធារណជន ។

អតិថិជនអាចផ្ញើបញ្ញើគ្រប់ប្រភេទក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា និងទៅអន្តរជាតិ លើកលែងតែវត្ថុដែលត្រូវហាមឃាត់ដូចខាងក្រោមនេះ :

ក-សម្ភារៈទាំងឡាយដែលវេចខ្ចប់មិនបានល្អ អាចបណ្តាលឱ្យមានគ្រោះថ្នាក់ ឬធ្វើឱ្យខូចខាតដល់បញ្ញើដទៃទៀត

ខ-គ្រឿងញៀនគ្រប់ប្រភេទនិងប្រភេទទំនិញដទៃទៀតដែលច្បាប់ហាមឃាត់

គ-រូបធាតុដែលអាចផ្ទុះ ងាយឆាបឆេះ ឬរូបធាតុផ្សេងៗទៀតដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់

ឃ-វត្ថុដែលមានភាពអាសអាភាស ប៉ះពាល់ដល់សីលធម៌សង្គម និងវត្ថុដែលមានខ្លឹមសារប៉ះពាល់ដល់ច្បាប់រដ្ឋ សន្តិសុខនិងរបៀបរៀបរយសង្គម

ង-វត្ថុដែលត្រូវហាមឃាត់ដោយប្រទេសទទួល ។

ការផ្ញើសត្វមានជីវិតត្រូវហាមឃាត់ លើកលែងតែ ឃ្មុំ ដង្កូវនាង ឈ្លើង និងបណ្តាអតិសុខុមប្រាណ ដោយតម្រូវឱ្យមានលិខិតបញ្ជាក់ជាផ្លូវការពីក្រសួងមានសមត្ថកិច្ចដែលត្រូវបានត្រួតពិនិត្យនិងអនុញ្ញាតតាមច្បាប់ ។

ធនប័ត្រ រូបិយប័ណ្ណ មាស ប្រាក់ ពេជ្រ ត្បូងមានតម្លៃនិងគ្រឿងអលង្ការធ្វើអំពីមាស ប្រាក់ ពេជ្រនិងត្បូង អាចផ្ញើបានតែតាមបញ្ញើប្រកាសតម្លៃ ។

**មាត្រា ២០.-**

រាល់បញ្ញើប្រៃសណីយ៍ត្រូវបានវេចខ្ចប់និងប្រកចូលបាវ កញ្ចប់ ឬហិបទំនិញដែលមានផ្លាកប្រៃសណីយ៍កម្ពុជា ។ កញ្ចប់ បាវ ហិបទំនិញ នោះត្រូវចង និងភ្ជិតដោយត្រាអាចម៍ល័ខ ឬកិបសំណ ដែលមានសញ្ញាសំគាល់របស់ប្រៃសណីយ៍ និងស្លាកបញ្ជាក់ពីទិសដៅត្រូវបញ្ជូនទៅ ។

មាត្រា ២១.-

រាល់វត្ថុបញ្ញើជាកញ្ចប់តូច ឬជាប្រៃសណីយ៍ភណ្ឌ ត្រូវទទួលការពិនិត្យផ្ទាល់ពីមន្ត្រីនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មុននឹងកញ្ចប់នោះត្រូវបិទ និងទទួលយកជាបញ្ញើប្រៃសណីយ៍ ។

ចំពោះវត្ថុណាដែលជាប់ពន្ធ តម្រូវឱ្យមានលិខិតបញ្ជាក់ច្បាស់លាស់ថាបានបង់ពន្ធរួចរាល់ត្រឹមត្រូវពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទើបអនុញ្ញាតទទួលជាបញ្ញើប្រៃសណីយ៍បាន ។

មាត្រា ២២.-

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចេញប្រកាសរួមកំណត់បែបបទនៃសេវាបញ្ញើប្រាក់តាមប្រៃសណីយ៍ក្នុងប្រទេស និងការបង្វែរប្រាក់ពីធនាគារឱ្យមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ទូទាំងប្រទេស ។ ចំពោះអាណត្តិប្រៃសណីយ៍អន្តរជាតិ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងធនាគារជាតិត្រូវកំណត់បែបបទក្នុងការបង្វែរប្រាក់ពីប្រទេសមួយទៅប្រទេសមួយ និងអត្រាប្ដូរប្រាក់ចំពោះអ្នកផ្ញើ និងអ្នកទទួលអាណត្តិប្រៃសណីយ៍ ។

## ជំពូកទី ៥
## អាជ្ញាប័ណ្ណអាជីវកម្មប្រៃសណីយ៍

មាត្រា ២៣.-

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍អាចចេញអាជ្ញាប័ណ្ណឱ្យឯកជនធ្វើអាជីវកម្មខាងវិស័យប្រៃសណីយ៍ ក្រៅពីសេវាប្រៃសណីយ៍ដែលស្ថិតក្រោមអាជីវកម្មរបស់រដ្ឋដើម្បីជួយបំពេញ និងទ្រទ្រង់សេវាប្រៃសណីយ៍ទាំងអស់ជូនប្រជាពលរដ្ឋ ។

លក្ខខណ្ឌលើការចេញអាជ្ញាប័ណ្ណ ការកែសម្រួល ការព្យួរ ការដកហូត ឬការបដិសេធ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**មាត្រា ២៤.-**

គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយអាចធ្វើអាជីវកម្មខាងវិស័យប្រៃសណីយ៍ដោយគ្មានអាជ្ញាប័ណ្ណមានសុពលភាពដែលបានចេញដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលបាននូវអាជ្ញាប័ណ្ណខាងលើមានសិទ្ធិធ្វើអាជីវកម្មខាងវិស័យប្រៃសណីយ៍ក្នុងកំរិតជាក់លាក់និងត្រឹមត្រូវតាមខ្លឹមសារនៃអាជ្ញាប័ណ្ណនោះតែប៉ុណ្ណោះ ។

**មាត្រា ២៥.-**

អាជ្ញាប័ណ្ណត្រូវចេញឱ្យតែចំពោះបុគ្គលណាដែលមានសមត្ថភាពសមស្របទៅនឹងល័ក្ខខ័ណ្ឌតម្រូវរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីដំណើរការជាក្រុមហ៊ុនសេវាកម្មប្រៃសណីយ៍ និងដើម្បីបំពេញកាតព្វកិច្ចនិងល័ក្ខខ័ណ្ឌសេវាកម្មដែលមានកំណត់នៅក្នុងអាជ្ញាប័ណ្ណនោះ ។

អ្នកកាន់អាជ្ញាប័ណ្ណនីមួយៗ ត្រូវគោរពល័ក្ខខ័ណ្ឌទាំងឡាយដែលមានចែងក្នុងអាជ្ញាប័ណ្ណរបស់ខ្លួន លិខិតបទដ្ឋាននានារបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ព្រមទាំងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៦.-**

អ្នកកាន់អាជ្ញាប័ណ្ណមិនអាច ជួល លក់ ឬបញ្ចាំអាជ្ញាប័ណ្ណរបស់ខ្លួនទៅឱ្យជនណាផ្សេងទៀតបានឡើយ ។ ការបោះបង់ ឬការផ្ទេរអាជ្ញាប័ណ្ណរបស់ខ្លួនឱ្យទៅជនណាផ្សេងទៀតអាចធ្វើទៅបានលុះត្រាតែមានការអនុញ្ញាតជាថ្មីពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**មាត្រា ២៧.-**

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ អាចផ្តល់សិទ្ធិឱ្យរូបវន្តបុគ្គលធ្វើជាកក្តាប្រៃសណីយ៍នៅតាមជនបទ ដែលពុំទាន់មានទីស្នាក់ការប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីសម្រួលដល់ការទទួល និងចែកចាយបញ្ញើឱ្យបានទូទាំងប្រទេស ។ កក្តាប្រៃសណីយ៍នេះជាមន្ត្រីជាប់កិច្ចសន្យារបស់ក្រសួង ។

លក្ខខណ្ឌនៃការផ្តល់សិទ្ធិនេះ និងលក្ខន្តិកៈរបស់ភ្នាក់ងារប្រៃសណីយ៍ជាប់កិច្ចសន្យា ព្រមទាំងភារកិច្ច និងប្រាក់កម្រៃត្រូវកំណត់ដោយប្រកាសរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

មាត្រា ២៨.-

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អាចផ្តល់សិទ្ធិឱ្យរូបវន្តបុគ្គលធ្វើជាភ្នាក់ងារប្រៃសណីយ៍ សំរាប់ទទួលលក់តែមប្រៃ និងផលិតផលប្រៃសណីយ៍ ដើម្បីសំរួលសេវាប្រៃសណីយ៍ទូទាំងប្រទេស ។

លក្ខខណ្ឌនៃការផ្តល់សិទ្ធិឱ្យធ្វើជាភ្នាក់ងារប្រៃសណីយ៍ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

## ជំពូកទី ៦
## កិច្ចសហការខាងប្រៃសណីយ៍ និងគយ

មាត្រា ២៩.-

ភ្នាក់ងារគយប្រចាំការនៅគ្រប់ច្រកចេញ-ចូលអន្តរជាតិ តាមផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស ត្រូវសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ លើវិស័យប្រៃសណីយ៍ ក្នុងការងារសម្រួលឱ្យកញ្ចប់ បាវនិងកុងតឺន័រនៃបញ្ញើប្រៃសណីយ៍គ្រប់ប្រភេទ ដែលត្រូវបញ្ជូនចេញនិងទទួលពីបរទេស ដោយផ្តល់អាទិភាពនិងពុំឆ្លងកាត់ការធ្វើប្រតិវេទន៍គយ ។

មាត្រា ៣០.-

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវផ្តល់ឱ្យភ្នាក់ងារគយប្រចាំការនៅការិយាល័យប្តូរបញ្ញើអន្តរជាតិ នូវកាលវិភាគបិទ ឬកាត់បាវអន្តរជាតិដើម្បីរួមគ្នាត្រួតពិនិត្យ ដោយអនុលោមតាមមាត្រា ៩ ដល់មាត្រា ១៣ នៃច្បាប់នេះ ។ ក្នុងករណីអវត្តមានភ្នាក់ងារគយ ភ្នាក់ងារប្រៃសណីយ៍ អាចកាត់បាវ ឬបិទបាវបញ្ញើដែលមានអាទិភាពខ្ពស់ រួចបញ្ជូន ឬចែកចាយដល់អ្នកទទួល ។

មាត្រា ៣១.-

ភ្នាក់ងារគយនិងមន្ត្រីប្រៃសណីយ៍ត្រូវសហការគ្នាពិនិត្យក្នុងកញ្ចប់ប្រៃសណីយ៍កណ្ដុ ឬកញ្ចប់ធម្មតាផ្ញើចេញឬផ្ញើចូលពីបរទេស ដើម្បីធ្វើបែបបទគយក្នុងការនាំចេញ ឬនាំចូល លើកលែងតែបញ្ញើបន្ត បញ្ញើខុសទិសដៅ និងបញ្ញើសំណល់ ។ ក្នុងការត្រួតពិនិត្យនេះ ភ្នាក់ងារគយត្រូវអនុវត្តនៅចំពោះមុខមន្ត្រីប្រៃសណីយ៍ និងអ្នកផ្ញើ ឬអ្នកទទួលនៅមន្ទីរប្រៃសណីយ៍ខេត្ត-ក្រុង ។

មាត្រា ៣២.-

ភ្នាក់ងារគយត្រូវផ្ដល់តារាងទំនិញហាមឃាត់ ទំនិញជាប់ពន្ធគយ និងតារាងតម្លៃពន្ធនាំចេញ ឬនាំចូល ព្រមទាំងកំណត់អំពីបរិមាណទំនិញដែលត្រូវជាប់ពន្ធ ។ តារាងនេះត្រូវបិទផ្សាយជាសាធារណៈនៅតាមគ្រប់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍។

## ជំពូកទី ៧

## ការដឹកជញ្ជូនបញ្ញើ

មាត្រា ៣៣.-

ការដឹកជញ្ជូនបញ្ញើប្រៃសណីយ៍ធ្វើតាមមធ្យោបាយ ផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ចែកជាដំណាក់កាលដូចខាងក្រោម :

១-ការដឹកជញ្ជូនបញ្ញើសំបុត្រប្រៃសណីយ៍ពីប្រអប់សំបុត្រតាមផ្លូវសាធារណៈ និងបញ្ញើប្រៃសណីយ៍ពីលំនៅដ្ឋាន ឬការិយាល័យមកមន្ទីរប្រៃសណីយ៍

២-ការដឹកជញ្ជូនបញ្ញើប្រៃសណីយ៍ពីមន្ទីរប្រៃសណីយ៍មួយទៅកាន់មន្ទីរប្រៃសណីយ៍ផ្សេងៗទៀត

៣-ការដឹកជញ្ជូនបញ្ញើប្រៃសណីយ៍ទៅចែកចាយដល់អាស័យដ្ឋានអ្នកទទួល

៤-ការដឹកជញ្ជូនបញ្ញើប្រៃសណីយ៍ពីព្រះរាជាណាចក្រកម្ពុជា ចេញទៅបណ្ដាប្រទេសនៅលើពិភពលោក ។

ការដឹកជញ្ជូនបញ្ញើប្រៃសណីយ៍អាចត្រូវបានធ្វើឡើងតាមរយៈមធ្យោបាយដឹកជញ្ជូនរបស់ក្រុមហ៊ុនដឹកជញ្ជូនរបស់រដ្ឋ ឬឯកជន ដោយផ្អែកលើកិច្ចព្រមព្រៀងដោយឡែករវាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រុមហ៊ុនដឹកជញ្ជូន ។ ចំពោះតម្លៃដឹកជញ្ជូន ត្រូវគិតទៅតាមតម្លៃអនុគ្រោះ ។

**មាត្រា ៣៤.-**

បញ្ញើប្រៃសណីយ៍ត្រូវបានរៀបចំឱ្យមានសុវត្ថិភាពពីមន្ទីរប្រៃសណីយ៍ដែលបញ្ជូនចេញ ហើយត្រូវបានធានាការពារយ៉ាងហ្មត់ចត់ក្នុងពេលដឹកជញ្ជូនដោយពុំអនុញ្ញាតឱ្យភ្នាក់ងារណាធ្វើការត្រួតពិនិត្យ ឆែកឆេរ ឬរាំងស្ទះការដឹកជញ្ជូននេះបានឡើយ ។

ក្នុងករណីមានការសង្ស័យពាក់ព័ន្ធនឹងការអង្កេតព្រហ្មទណ្ឌ ភ្នាក់ងារមានសមត្ថកិច្ចអាចធ្វើដំណើរអមការដឹកជញ្ជូននេះ រហូតដល់មន្ទីរប្រៃសណីយ៍ដែលជាគោលដៅនៃការដឹកជញ្ជូន ។ អ្នកទទួលខុសត្រូវនៃមន្ទីរប្រៃសណីយ៍នោះត្រូវរៀបចំចាត់ចែងឱ្យមានការត្រួតពិនិត្យចំពោះតែបញ្ញើណាដែលជាប់សង្ស័យដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងតាមនីតិវិធីព្រហ្មទណ្ឌដែលមានជាធរមាន ។

**មាត្រា ៣៥.-**

ការប្រគល់និងការទទួលយកបញ្ញើប្រៃសណីយ៍ដែលផ្ញើទៅបរទេសឬមកពីបរទេស ត្រូវធ្វើឡើងភ្លាមៗនិងដោយផ្ទាល់រវាងភ្នាក់ងារដឹកជញ្ជូន និងភ្នាក់ងារប្រៃសណីយ៍ ។

## ជំពូកទី ៨
## កិច្ចសហការជាមួយប្រៃសណីយ៍បរទេស

**មាត្រា ៣៦.-**

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវភ្ជាប់ទំនាក់ទំនងជាមួយបណ្តាញប្រៃសណីយ៍គ្រប់ប្រទេស និងគោរពអនុវត្តទៅតាមសេចក្តីសំរេចទាំងឡាយដែលបានកំណត់ដោយសហភាពប្រៃសណីយ៍សកលដើម្បីធានានូវបរន្តការប្រៃសណីយ៍ជាមួយអន្តរជាតិ ។

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវកំណត់អំពីការបែងចែក ការទទួលខុសត្រូវក្នុងក្របខ័ណ្ឌអន្តរជាតិ ដើម្បីធានានូវប្រសិទ្ធភាពខ្ពស់និងឯកភាពទូទាំងពិភពលោក ។

**មាត្រា ៣៧.-**

ក្រោយពីបានទទួលសិទ្ធិប្រទានពីរាជរដ្ឋាភិបាល តាមករណីនីមួយៗ ការធ្វើអាជីវកម្មប្រៃសណីយ៍អន្តរជាតិ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍មានសិទ្ធិចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាទ្វេភាគី ឬពហុភាគីលើវិស័យបច្ចេកទេសប្រៃសណីយ៍ជាមួយបណ្តាប្រទេសលើពិភពលោកដោយអនុលោមទៅតាមសេចក្តីសំរេចរបស់សហភាពប្រៃសណីយ៍សកលនិងប្រៃសណីយ៍ប្រចាំតំបន់ ។

## ជំពូកទី ៩
## ការទទួលខុសត្រូវលើបញ្ញើប្រៃសណីយ៍ និងសិទ្ធិតវ៉ា

**មាត្រា ៣៨.-**

ប្រៃសណីយ៍កម្ពុជាព្រមទាំងនីតិបុគ្គល និងរូបវ័ន្តបុគ្គលដែលបំរើសេវាកម្មវិស័យប្រៃសណីយ៍ ដូចមានចែងក្នុងជំពូកទី៥នៃច្បាប់នេះ ត្រូវទទួលខុសត្រូវលើគ្រប់បញ្ញើប្រៃសណីយ៍ចំពោះការខូចខាតណាដែលកើតឡើងដោយការប្រតិបត្តិសេវាកម្មមិនបានត្រឹមត្រូវ ។

ក្នុងករណីបាត់បង់ ឬខូចខាតដោយប្រការខាងលើ ប្រៃសណីយ៍កម្ពុជា និងនីតិបុគ្គលដែលបំរើសេវាកម្មវិស័យប្រៃសណីយ៍ ទទួលសងតែចំពោះ :

- បញ្ញើសំបុត្រប្រៃសណីយ៍ ដែលធ្វើជាអនុសិដ្ឋ ឬជាបញ្ញើធានារ៉ាប់រងពិសេស
- បញ្ញើប្រៃសណីយ៍ភណ្ឌ
- បញ្ញើមានប្រកាសតម្លៃ និង
- ប្រៃសណីយ៍បញ្ជូនប្រាក់ ។

បញ្ញើមួយដែលចាត់ទុកថាជាបញ្ញើបាត់បង់បាន លុះត្រាតែបញ្ញើនោះក្នុងអំឡុងពេលជាកំណត់ មិនបានទៅដល់ដៃអ្នកទទួល ហើយពុំត្រូវបានរកឃើញថា បញ្ញើនោះស្ថិតនៅទីណា ។

បញ្ញើមួយដែលចាត់ទុកថាខូចខាតបាន លុះត្រាតែវត្ថុក្នុងនោះត្រូវបានផ្លាស់ប្តូរ

សភាពដើម និងបណ្ដាលឱ្យចុះថយតម្លៃដើមរបស់វា ។

សំណងនៃការខូចខាត ឬបាត់បង់ត្រូវប្រគល់ឱ្យអ្នកផ្ញើ ឬអ្នកទទួលតាមសំណើរបស់អ្នកផ្ញើ ។

អ្នកផ្ញើ ឬអ្នកទទួលមានសិទ្ធិធ្វើបណ្ដឹងតវ៉ាអំពីបញ្ញើដែលបាត់បង់ ឬឱ្យសងក្នុងករណីបញ្ញើបាត់បង់ ឬខូចខាត ដាក់ជូនមន្ទីរប្រៃសណីយ៍នៅទីណាមួយក៏បាន ។ បណ្ដឹងតវ៉ានេះត្រូវធ្វើក្នុងអំឡុងពេល ៦ខែ គិតចាប់ពីថ្ងៃផ្ញើ ។

**មាត្រា ៣៩.-**

ការទទួលខុសត្រូវរបស់ប្រៃសណីយ៍កម្ពុជាព្រមទាំងនីតិបុគ្គល និងរូបវន្តបុគ្គលដែលបំពេញសេវាកម្មវិស័យប្រៃសណីយ៍ ដូចមានចែងក្នុងមាត្រា ៣៨ នៃច្បាប់នេះត្រូវបានលើកលែង ប្រសិនបើការបាត់បង់ឬការខូចខាតណាមិនត្រូវបានកើតឡើងដោយសារចេតនា ឬការធ្វេសប្រហែសក្នុងការបំពេញភារកិច្ចរបស់ខ្លួនដូចជា :

១- បញ្ញើត្រូវបានបាត់បង់ ឬខូចខាតក្នុងករណីប្រធានសក្តិ

២- បញ្ញើដែលពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌហើយត្រូវបានរឹបអូសដោយអាជ្ញាធរមានសមត្ថកិច្ច

៣- ក្នុងករណីដែលអ្នកផ្ញើ ឬអ្នកទទួលមិនបានប្ដឹងតវ៉ាមកប្រៃសណីយ៍ក្នុងរយៈ ៦ខែ គិតពីថ្ងៃផ្ញើបញ្ញើ ។

**មាត្រា ៤០.-**

ប្រៃសណីយ៍កម្ពុជា នីតិបុគ្គល និងរូបវន្តបុគ្គលដែលបំពេញសេវាកម្មវិស័យប្រៃសណីយ៍ទទួលខុសត្រូវចំពោះអ្នកផ្ញើ ក្នុងករណីមានការបាត់បង់នូវបញ្ញើសំបុត្រប្រៃសណីយ៍ដែលផ្ញើជាបញ្ញើអនុសិដ្ឋ ឬបញ្ញើឆាប់រហ័សពិសេស ។ សំណងនេះត្រូវកំរិតក្នុងតម្លៃមួយដែលកំណត់ដោយប្រកាសរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

ប្រៃសណីយ៍កម្ពុជា នីតិបុគ្គល និងរូបវន្តបុគ្គលដែលបំពេញសេវាកម្មវិស័យប្រៃសណីយ៍ទទួលខុសត្រូវចំពោះអ្នកផ្ញើ ក្នុងករណីមានការបាត់បង់ ឬខូចខាតនូវប្រៃសណីយ៍ភណ្ឌ ។ សំណងនេះត្រូវទូទាត់ស្មើនឹងតម្លៃនៃការខូចខាតរហូតដល់តម្លៃអតិបរមាមួយ ដែលកំណត់

ដោយប្រកាសរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

ប្រៃសណីយ៍កម្ពុជា និងនីតិបុគ្គលដែលបំពេញសេវាកម្មវិស័យប្រៃសណីយ៍ទទួលខុសត្រូវចំពោះអ្នកផ្ញើ ក្នុងករណីមានការបាត់បង់ ឬខូចខាតទូទាំងបញ្ញើប្រៃសណីយ៍ដែលមានការប្រកាសតម្លៃ ។ សំណងនេះត្រូវទូទាត់ស្មើនឹងតម្លៃនៃការខូចខាត ស្របតាមតម្លៃដែលបានប្រកាស ។

**មាត្រា ៤១.-**

ក្នុងករណីបញ្ញើបាត់បង់មួយត្រូវបានរកឃើញវិញ ក្រោយការទូទាត់សំណងបានធ្វើចប់សព្វគ្រប់ ត្រូវបញ្ជូនបញ្ញើនោះទៅអ្នកផ្ញើ ឬអ្នកទទួលតាមសំណូមពររបស់អ្នកផ្ញើហើយត្រូវទូទាត់សំណងនេះយកឱ្យប្រៃសណីយ៍វិញ ។ ប្រសិនបើអ្នកផ្ញើ និងអ្នកទទួលបដិសេធមិនទទួលយកបញ្ញើដែលបានរកឃើញវិញទេនោះ បញ្ញើនេះត្រូវចាត់ទុកជា បញ្ញើសំណល់ហើយប្រៃសណីយ៍មិនអាចទារសំណងមកវិញបានទេ ។

**មាត្រា ៤២.-**

ប្រៃសណីយ៍កម្ពុជា និងនីតិបុគ្គលដែលបំពេញសេវាកម្មវិស័យប្រៃសណីយ៍មិនទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើង :

- ពីធម្មជាតិនៃវត្ថុបញ្ញើនោះ
- ដោយអ្នកផ្ញើមិនបានវេចខ្ចប់វត្ថុឱ្យបានត្រឹមត្រូវ
- ដោយអ្នកទទួលមិនបានតវ៉ាភ្លាមៗ
- ក្រោយរយៈពេលជាកំណត់ដែលប្រៃសណីយ៍តម្រូវឱ្យអ្នកទទួលមកយកបញ្ញើ ឬ
- ក្រោយរយៈពេលជាកំណត់ដែលប្រៃសណីយ៍តម្រូវឱ្យអ្នកផ្ញើមកយកបញ្ញើក្នុងករណីបញ្ញើមិនដល់គោលដៅ ឬអ្នកទទួលបដិសេធមិនទទួលយកបញ្ញើ ។

មាត្រា ៤៣.-

អ្នកទទួលបញ្ញើមានសិទ្ធិប្រកែកមិនទទួលយកបញ្ញើ ។

ចំពោះការប្រកែកមិនទទួលយកបញ្ញើសំបុត្រប្រៃសណីយ៍ធម្មតា អ្នកទទួលបញ្ញើអាចបញ្ជូនទៅប្រៃសណីយ៍ឱ្យផ្ញើត្រឡប់ទៅអ្នកផ្ញើវិញ ។

ចំពោះការប្រកែកមិនទទួលយកបញ្ញើសំបុត្រប្រៃសណីយ៍ ដែលផ្ញើជាបញ្ញើអនុសិដ្ឋ ឬជាបញ្ញើឆាប់រហ័សពិសេស ក៏ដូចជាបញ្ញើប្រៃសណីយ៍ភណ្ឌ និងបញ្ញើមានប្រកាសតម្លៃ ត្រូវធ្វើឡើងរយៈពេលប្រាំពីរថ្ងៃ ក្រោយពីបានទទួលលិខិតជូនដំណឹងរបស់ប្រៃសណីយ៍ឬក្នុងខណៈពេលនៃការប្រគល់បញ្ញើផ្ទាល់ដៃ ។

ក្នុងករណីអ្នកទទួលបញ្ញើប្រកែកមិនទទួលយកបញ្ញើ ប្រៃសណីយ៍ត្រូវបោះត្រាបញ្ជាក់ថាមិនព្រមទទួល ហើយត្រូវបញ្ជូនបញ្ញើនេះទៅអ្នកផ្ញើវិញ ។ តម្លៃសេវាប្រៃសណីយ៍នៃការផ្ញើត្រឡប់ទៅវិញនោះជាបន្ទុករបស់អ្នកផ្ញើដើម ។

មាត្រា ៤៤.-

ប្រៃសណីយ៍កម្ពុជា និងនីតិបុគ្គលដែលបំរើសេវាកម្មវិស័យប្រៃសណីយ៍ទទួលខុសត្រូវអំពីការទទួល និងការប្រគល់ប្រាក់បញ្ញើតាមសេវាបញ្ជូនប្រាក់តាមប្រៃសណីយ៍ ។

## ជំពូកទី ១០
## ទោសប្បញ្ញត្តិ

មាត្រា ៤៥.-

ត្រូវពិន័យជាប្រាក់ពី ៥០០.០០០ (ប្រាំសែន) រៀល ដល់ ២.០០០.០០០ (ពីរលាន) រៀល ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១២ និង មាត្រា ១៣ នៃច្បាប់នេះ ដោយពុំទាន់គិតដល់សំណងរដ្ឋប្បវេណី ។ ក្នុងករណីមិនរាងចាល ត្រូវពិន័យជាប្រាក់ទ្វេដង ។

មាត្រា ៤៦.-

ជនទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ១៩ នៃច្បាប់នេះ ត្រូវទទួលការពិន័យ និង/ឬផ្តន្ទាទោសអាស្រ័យនឹងទង្វើ និងបទល្មើសដូចខាងក្រោម :

- ពិន័យជាប្រាក់ពី៥០.០០០ (ហាសិបម៉ឺន)រៀល ដល់១៥០.០០០ (មួយសែនហាសិបម៉ឺន)រៀល ចំពោះទង្វើដូចចែងក្នុងវាក្យខណ្ឌ ២ ចំណុច ក ឬចំណុច គ ឬ ចំណុច ឃ ដោយពុំទាន់រាប់បញ្ចូលនូវសំណងវត្ថុប្បវេណីលើការខូចខាតនៃបញ្ញើផងទៃ និងទោសព្រហ្មទណ្ឌ ដោយសារការបណ្តាលឱ្យមានគ្រោះថ្នាក់

- ត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចំពោះបទល្មើសដូចចែងក្នុងវាក្យខណ្ឌ ២ ចំណុច ខ

- ពិន័យជាប្រាក់ពី៥០០.០០០ (ប្រាំសែន) រៀល ដល់ ១.៥០០.០០០ (មួយលានប្រាំសែន)រៀល ចំពោះទង្វើល្មើសនឹងវាក្យខណ្ឌ ៤ ។

មាត្រា ៤៧.-

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ខែ ដល់១២ខែ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ដល់ ៥.០០០.០០០(ប្រាំលាន)រៀល ចំពោះជនទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣៤ វាក្យខណ្ឌ ១ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ដល់ ១៨ខែ ចំពោះជនទាំងឡាយណាដែលរក្សាទុកបញ្ញើ ឬចាវប្រៃសណីយ៍ដោយគ្មានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ក្នុងបំណងលាក់ពាំង ឬដកហូតវត្ថុអ្វីមួយពីក្នុងនោះ ។ ក្នុងករណីជនល្មើសជាមន្ត្រីប្រៃសណីយ៍ ត្រូវដាក់វិន័យរដ្ឋបាលបន្ថែមទៀត ។

មាត្រា ៤៨.-

ត្រូវពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន)រៀល ចំពោះជនណាដែលធ្វើអាជីវកម្មលើវិស័យប្រៃសណីយ៍ ដោយគ្មានអាជ្ញាប័ណ្ណដូចមានចែងក្នុងមាត្រា ២៤ វាក្យខណ្ឌ ១ នៃច្បាប់នេះ ហើយត្រូវបញ្ឈប់អាជីវកម្មខុសច្បាប់នេះជាបន្ទាន់ ដោយប្រកាសរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។ ករណីមិន

រាជរដ្ឋាភិបាលត្រូវបញ្ជូនសំណុំរឿងទៅតុលាការ ។

ត្រូវពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន)រៀល ដល់ ១០.០០០.០០០ (ដប់លាន)រៀល អ្នកកាន់អាជ្ញាប័ណ្ណប្រៃសណីយ៍ មិនគោរពតាមបញ្ញត្តិ ដូចមានចែងក្នុងមាត្រា ២៤ វាក្យខ័ណ្ឌ ២ និងមាត្រា ២៥ វាក្យខ័ណ្ឌ ២ នៃច្បាប់នេះ ។ ករណីមិនរាងចាលត្រូវដកហូតអាជ្ញាប័ណ្ណដោយប្រកាសរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

អ្នកកាន់អាជ្ញាប័ណ្ណប្រៃសណីយ៍ មិនគោរពតាមបញ្ញត្តិដូចមានចែងក្នុងមាត្រា ២៦ នៃច្បាប់នេះ ត្រូវពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន)រៀល ដល់ ២០.០០០.០០០ (ម្ភៃលាន)រៀល ហើយត្រូវដកហូតអាជ្ញាប័ណ្ណ ។

**មាត្រា ៤៩.-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥.០០០.០០០ (ប្រាំលាន)រៀល ដល់ ២០.០០០.០០០ (ម្ភៃលាន)រៀល និង/ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ចំពោះជនទាំងឡាយណាដែលធ្វើតាម ឬក្លែងបន្លំតែមប្រើប្រៃសណីយ៍ ឬផលិតផលប្រៃសណីយ៍ផ្សេងៗទៀត ។

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន)រៀល ដល់ ៥.០០០.០០០ (ប្រាំលាន) រៀល ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ ចំពោះជនណាដែលបានធ្វើអាជីវកម្មតែមប្រើប្រៃសណីយ៍ក្លែងក្លាយ ឬប្រើប្រាស់ត្រា ឬសញ្ញាសំគាល់ប្រៃសណីយ៍ដោយខុសច្បាប់ ។

វត្ថុក្លែង និងឧបករណ៍នៃការប្រព្រឹត្តិល្មើស ត្រូវរឹបអូស និងបំផ្លាញចោលតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៥០.-**

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវដាក់ទណ្ឌកម្មរដ្ឋបាល ដោយពុំទាន់គិតពីសំណងរដ្ឋប្បវេណី ឬទោសព្រហ្មទណ្ឌ ចំពោះមន្ត្រីប្រៃសណីយ៍ណាដែល :

- យកតម្លៃសេវាប្រៃសណីយ៍មិនត្រឹមត្រូវតាមតម្លៃពិត ដែលកំណត់ដោយប្រកាសរបស់ក្រសួង
- ទាមទារយកកំរៃបន្ថែមដោយខុសច្បាប់ពីអ្នកទទួល ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**មាត្រា ៥១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០០២

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

៣រល.០២.០៧.០០៤៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

**ហត្ថលេខា**

**សូ ឃុន**

លេខ : ១៧១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ីវ៉ា តាន់**